**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១០៥/០០៥/២០០៦

ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**

លេខ : ០៧៧/០០៤/២០០៦ កបធ.ច

ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៥៤/០៥០៦/ពស/នវ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០០៦ របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ វេលាម៉ោង ១៤ : ១០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ថ្មីនៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌទី២ ឃ្លាទី១ ចែងថា" *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ*" ។ សំណើរបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា លេខ០៥៤/០៥០៦/ពស/នវ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ វេលាម៉ោង ១៤:១០នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

- យល់ឃើញថា មាត្រា ១០៦ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ បានប្រគល់ឱ្យព្រឹទ្ធសភា (មិនមែនការិយាល័យបណ្ដោះអាសន្នទេ) ប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗនិងបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភានិង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល
- យល់ឃើញថា ប្រការ ៥ ចំណុច ២ ដែលចែងថា " *ការិយាល័យបណ្ដោះអាសន្នមានភារកិច្ចជ្រើសតាំងប្រធាន និង អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា* " ផ្ទុយនឹងមាត្រា ១០៦ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ ពីព្រោះការិយាល័យបណ្ដោះអាសន្នមានសិទ្ធិរៀបចំការបោះឆ្នោតជ្រើសតាំងប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភាតែប៉ុណ្ណោះ ។ ការជ្រើសតាំងប្រធាន និង អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ជាភារកិច្ចរបស់ព្រឹទ្ធសភា
- យល់ឃើញថា ប្រការ ១៩ កថាខណ្ឌទី២ ដែលចែងថា " *ក្នុងករណីពិសេសបន្ទាន់ ដែលមិនអាចបោះឆ្នោតដាច់ដោយឡែកពីគ្នាបាន ការបោះឆ្នោតអាចធ្វើឡើងក្នុងពេលតែមួយ មានទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ បាន ។ សន្លឹកឆ្នោត ត្រូវធ្វើដាច់ដោយឡែកពីគ្នា* " ផ្ទុយនឹងមាត្រា ១០៦ ថ្មី (មួយ) កថាខណ្ឌទី២នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *មុនចាប់ផ្ដើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និង ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល* " តែប៉ុណ្ណោះ
- យល់ឃើញថា ប្រការ២០ ដែលចែងថា " *កាលបើជ្រើសរើសប្រធាន និង អនុប្រធានបានហើយ ប្រធានការិយាល័យបណ្ដោះអាសន្ន ត្រូវប្រកាសបញ្ចប់ភារកិច្ចរបស់ការិយាល័យបណ្ដោះអាសន្ន ហើយប្រគល់ការងារជូនប្រធានព្រឹទ្ធសភាដែលទើបបានជ្រើសតាំង* " ផ្ទុយនឹងមាត្រា ១០៦ ថ្មី (មួយ) កថាខណ្ឌទី២នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *មុនចាប់ផ្ដើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និង ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល* "
- យល់ឃើញថា ប្រការ ២៥ ផ្ទុយនឹងមាត្រា ១០៦ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ប្រការ ១០៩ កថាខណ្ឌទី២ បានចែងថា " *ក្នុងករណីទុញទាល់ពុំមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះទេ ប្រធានព្រឹទ្ធសភាត្រូវសុំការសម្រេចពីគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ ពី*

*សម័យប្រជុំពេញអង្គអំពីនីតិវិធីសមស្រប ដែលត្រូវយកមកអនុវត្ត*" នោះ មានលក្ខណៈផ្ទុយនឹងមាត្រា១៤០ថ្មី កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញដែលចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ* "

- យល់ឃើញថា នៅក្នុងគ្រប់ជំពូក និង ប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភា ពុំមានបទបញ្ញត្តិណាដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែបទបញ្ញត្តិនៃប្រការ ៥ ចំណុច **ខ** ប្រការ ១៩ កថាខណ្ឌទី២ ប្រការ២០ ប្រការ២៥ និង ប្រការ ១០៩ កថាខណ្ឌទី២ ។

## សម្រេច

**មាត្រា ១.-** បទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី១ នីតិកាលទី២ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៥ ចំណុច **ខ**ដែលមិនស្របនឹងមាត្រា ១០៦ថ្មី ( មួយ) នៃរដ្ឋធម្មនុញ្ញ ប្រការ ១៩ កថាខណ្ឌទី២ ប្រការ២០ ប្រការ ២៥ មិនស្របនឹងមាត្រា ១០៦ថ្មី ( មួយ) កថាខណ្ឌទី២នៃរដ្ឋធម្មនុញ្ញ និង ប្រការ ១០៩ កថាខណ្ឌទី២ មិនស្របនឹងមាត្រា១៤០ ថ្មី កថាខណ្ឌទី២នៃរដ្ឋធម្មនុញ្ញ។

**មាត្រា ២.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០១ខែ មិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន